# នៅពេលណាគេរក្សាទុកប្រាក់ពន្ធរបស់អ្នក ដែលត្រូវបានមក

**WHEN THEY KEEP YOUR TAX REFUND**

## តើការឃាត់ទុកថវិការគឺជាអ្វី?

ក្រសួងហិរញ្ញវត្ថុរដ្ឋមិនីសូតាអាចរក្សាទុកប្រាក់ពន្ធរបស់អ្នកដែលត្រូវបានមកពីធ្វើពន្ធប្រាក់ចំណូលឬទ្រព្យសម្បត្តិ, ឬពីរង្វាន់ឆ្នោត បើអ្នក ជំពាក់ប្រាក់រដ្ឋឬខោនធី។ ក្រសួងពន្ធដារផ្ញើប្រាក់ដែលត្រូវបានរបស់អ្នក ទៅក្រសួងដែលអ្នកជំពាក់ប្រាក់។ នេះហៅថា "ការឃាត់ទុកថវិការ"។ គេធ្វើយ៉ាងនេះដើម្បីប្រមូលប្រាក់ជំនួយរដ្ឋដែលឲ្យលើស, ថ្លៃពេទ្យពីខោនធីឬពីមន្ទីរពេទ្យក្រុង, បំណុលសាលា,ប្រាក់ចិញ្ចឹមក្មេង, និងពិន័យឬសំណងក្នុងបទឧក្រិដ្ឋផ្សេងៗ។

## តើនៅពេលណា ប្រាក់ដែលត្រូវបាននោះ ត្រូវបានការពារពីការឃាត់ទុកនោះ?

ទោះបីជាអ្នកជំពាក់ប្រាក់ក៏ដោយ, គេមិនអាចយកប្រាក់ដែលត្រូវបានរបស់អ្នកទេ បើ:

- បំណុលរបស់អ្នកសំរាប់ថ្លៃពេទ្យ,ហើយប្រាក់ខែរបស់អ្នក**នៅពេលដែលអ្នកបានទទួលការព្យាបាលផ្នែកពេទ្យ**មានចំនួនក្រោមកំរិតមួយ។ កំរិតនេះប្តូររាល់ឆ្នាំ។ ឧទាហរណ៍, បើថ្លៃពេទ្យនោះមានពីឆ្នាំ **2000,** ហើយប្រាក់ចំណូលរបស់អ្នកក្នុងឆ្នាំ2000ត្រូវតែមាន:
  - $8,800 ឬតិចជាងសំរាប់បុគ្គលម្នាក់;
  - $11,270 ឬតិចជាងសំរាប់បុគ្គលម្នាក់និងមានមនុស្សក្នុងបន្ទុក 1នាក់;
  - $13,330 ឬតិចជាងសំរាប់បុគ្គលម្នាក់និងមានមនុស្សក្នុងបន្ទុក 2នាក់;

  សូមហៅទៅក្រសួងហិរញ្ញវត្ថុលេខ (651) 296-3781 ដើម្បីទទួលចំនួនកំណត់សំរាប់ឆ្នាំ ផ្សេងៗ ឬសំរាប់ចំនួនមនុស្សក្នុងបន្ទុកច្រើនជាង 2នាក់។

- បំណុលរបស់អ្នកគឺសំរាប់ការឲ្យប្រាក់លើសពីជំនួយរដ្ឋ ហើយអ្នកនៅតែទទួលជំនួយរដ្ឋ។ នេះ មានន័យថា MFIP, GA, ប្រាក់ជំនួយថ្លៃមើលក្មេងនិងអ្វីដែលស្រដៀងគ្នា។ តែគេ**អាច**យក ប្រាក់ដែលត្រូវបានរបស់អ្នក នៅពេលដែលអ្នកកំពុងទទួលជំនួយ បើអ្នកត្រូវបានឲ្យលើស ដោយសារអ្នកបានកុហក ឬមានបំណងបំពានលើច្បាប់នៃកម្មវិធីជំនួយ។



- អ្នកមានគំរោងសងប្រាក់ជាមួយក្រសួង, អ្នកបានរក្សាការបង់ថ្លៃនេះជានិច្ច **និង** គំរោងនោះបញ្ជាក់ថាគេនឹងមិនប្រើ ការឃាត់ទុកនេះទេ,

- បំណុលរបស់អ្នកមានរយះច្រើនជាង 6 ឆ្នាំ។ គេមានការលើកលែងខ្លះចំពោះច្បាប់នេះ។ ឧទាហរណ៍, គេអាចឃាត់ទុកប្រាក់បំណុលកម្ចីសិស្សសូម្បីហួស 6 ឆ្នាំក៏ដោយ។

ក្នុងករណីទាំងអស់ខាងលើ, គេមិនអាចយកប្រាក់ដែលអ្នកត្រូវបាននោះទេ, ប៉ុន្តែអ្នកត្រូវតែប្រាប់គេដោយការសរសេរ។

## តើដំណឹងអ្វីដែលខ្ញុំគួរទទួល?

ដំបូងក្រសួងរដ្ឋឬខោនធីណាមួយ សុំឲ្យក្រសួងហិរញ្ញវត្ថុ យកប្រាក់ដែលអ្នកត្រូវបាននោះ។ បន្ទាប់មកក្នុងរយៈ 5 ថ្ងៃក្រសួងដែលគិតថា អ្នកជំពាក់ប្រាក់គេនោះ ត្រូវផ្ញើឲ្យអ្នកនូវដំណឹងមួយអំពីសិទ្ធិរបស់អ្នក។

ដំណឹងនោះត្រូវតែប្រាប់អ្នកថា:

- តើបំណុលនេះគឺសំរាប់អ្វី, ចំនួន, និងនៅពេលណាដែលបានកើតឡើង,
- គេចង់ប្រើការឃាត់ទុកថវិការ,
- អ្នកអាចជំទាស់អំពីបំណុលនោះ និងថាតើអ្នកគួរត្រូវគេប្រើការឃាត់ទុកថវិការនោះឬទេ,
- របៀបណាអ្នកអាចតវ៉ាការឃាត់ទុកថវិការនេះ,
- អ្នកអាចសុំវិនិច្ឆ័យសាថ្មីបាន។

## តើរបៀបធ្វើទំរង់ការសុំវិនិច្ឆ័យសាថ្មីយ៉ាងណា?



សរសេរទៅក្រសួងដែលថាអ្នកជំពាក់ប្រាក់គេ **មិនមែន**ទៅក្រសួងហិរញ្ញវត្ថុឡើយ។

ដាក់នៅខាងលើនៃ សំបុត្រ ថា "Revenue Recapture Appeal."

ពន្យល់ខ្លីៗថាហេតុអ្វីគេមិនគួរទុកប្រាក់ដែលអ្នក ត្រូវបាន។ មូលហេតុអាចថា

- អ្នកមិនមានជំពាក់ប្រាក់ទេ ឬ
- ទោះបីជាអ្នកជំពាក់ប្រាក់ក៏ដោយ,អ្នកត្រូវបានការពារពីការឃាត់ទុកនេះ សូមមើលខាងលើ។

**រក្សាទុកក្រដាសចម្លងសំបុត្រនេះ។** ក្រសួងត្រូវតែទទួលការសុំវិនិច្ឆ័យសាថ្មីរបស់អ្នកក្នុងរយៈពេល 45 ថ្ងៃ ពីថ្ងៃដែលដំណឹងរបស់គេនេះបានផ្ញើទៅឲ្យអ្នក។ ក្រសួងគួរតែដាក់ពេលធ្វើសវនាការមួយក្នុងរយៈពេល30 ថ្ងៃ។ អ្នកមិនត្រូវការមានមេធាវីទេ, តែអ្នកអាចទូរស័ព្ទទៅមេធាវីម្នាក់ដើម្បីរកយោបល់។

**អ្នកគ្មានសិទ្ធិដើម្បីធ្វើសវនាការទេ បើបំណុលនោះមកពីការកាត់ក្តីឬបញ្ជាពីតុលាការ។**

បើអ្នកមិនបានទទួលដំណឹងអំពីសិទ្ធិរបស់អ្នក ពីក្រសួងទេ អ្នកនៅតែអាចសុំធ្វើការវិនិច្ឆ័យសាថ្មីបាន:

- សរសេរទៅក្រសួងដើម្បីសុំធ្វើការវិនិច្ឆ័យសាថ្មីមួយ។
- ពេល45 ថ្ងៃសំរាប់សុំវិនិច្ឆ័យសាថ្មី គឺមិនទាន់ចាប់ផ្តើមរាប់ រហូតដល់ពេលអ្នកបានទទួលដំណឹងជាលាយលក្ខអក្សរថា គេចង់ប្រើការឃាត់ទុកថវិការនេះ។

បើក្រសួងថា គេបានផ្ញើដំណឹងមួយឲ្យអ្នក, តែអ្នកមិនដែលបានទទួលសោះ, ដូច្នេះអ្នកទទួលធ្វើសវនាការមួយ លើករណីពីរ។ ទីមួយ តើអ្នកពិតជាបានទទួលដំណឹងឬទេ? ទីពីរ តើគេអាចយកប្រាក់ដែលអ្នកត្រូវបាននោះ ឬទេ?

***Minneapolis Legal Aid – CLE***
*MN Legal Services Coalition*
*2324 University Avenue, Suite 101B*
*St. Paul, MN 55114*

***សូមកុំប្រើក្រដាសពត៌មាននេះបើក្រដាសនេះយូរជាងមួយឆ្នាំ។***
*សរសេរទៅយើងសុំក្រដាសថ្មីៗ បញ្ជីក្រដាសពត៌មាន ឬក្រដាសផ្សេងៗ។ក្រដាសពត៌មានមិនមែនជាចម្លើយសព្វគ្រប់សំរាប់ បញ្ហាច្បាប់ឡើយ។ សូមជួបជាមួយមេធាវីដើម្បីការសុំយោបល់។*

© 2011 Mid-Minnesota Legal Assistance. This document may be reproduced and used for non-commercial personal and educational purposes only. All other rights reserved. This notice must remain on all copies. Reproduction, distribution, and use for commercial purposes are strictly prohibited.